តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

# ការត្រួតពិនិត្យ ស្តីពីការបំភិតបំភ័យ និងអំពើហិង្សា

## របាយការណ៍ (សំរាប់រយៈពេលពីថ្ងៃទី ១០ ដល់ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ១៩៩៨)

នេះគឺជារបាយការណ៍ទី ៣ ដែលលាតត្រដាងស្ថានភាពការណ៍ជាក់ស្តែង ស្តីពីបញ្ហាសិទ្ធិមនុស្សដែលទាក់ទិនទៅនឹងការបំភិតបំភ័យ និងអំពើហិង្សានយោបាយ ។ របាយការណ៍នេះ ត្រូវបានចងក្រងឡើងដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ក្នុងនាមលោកតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គ-ការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ។ របាយការណ៍នេះ បានពិនិត្យឡើងវិញនូវរបាយការណ៍លើកមុន ២ ពោលគឺរបាយការណ៍ចុះថ្ងៃទី ១ ខែកក្កដា និងរបាយការណ៍ចុះថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ១៩៩៨ កន្លងទៅនេះ ។

របាយការណ៍នេះ ផ្តល់ព័ត៌មានស្តីពីស្ថានភាពនៃការស៊ើបអង្កេតទៅលើការចោទប្រកាន់អំពីអំពើហិង្សានយោ-បាយដែលជាការល្មើសទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ។ រហូតមកទល់នឹងពេលនេះ ការិយាល័យមិនទាន់អាចធ្វើសេចក្តីសន្និដ្ឋានណាមួយចំពោះករណីទាំងអស់នេះនៅឡើយទេ ប៉ុន្តែការស៊ើបអង្កេតកំពុងធ្វើជាបន្តទៅទៀត ។

សេចក្តីសង្ខេបៈ

ករណីឃាតកម្មមួយករណី ការប៉ុនប៉ងធ្វើឃាតពីរករណី និងការចោទប្រកាន់ដែលគួរឱ្យជឿបាននៃការបំភិត-បំភ័យ និងនៃអំពើហិង្សានយោបាយ ទាក់ទងទៅនឹងកិច្ចដំណើរការបោះឆ្នោត ត្រូវបានការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានទទួលដឹងឮ ចាប់តាំងពីថ្ងៃទី ៩ ខែកក្កដា មក ។ ការិយាល័យក៏បានបញ្ជាក់ផងដែរនូវការរកឃើញសាកសពមួយដែលមានស្លាកស្នាមនៃការធ្វើឃាតអណ្តែតទឹកទន្លេមេគុង នៅក្នុងស្រុកមុខកំពូល ក្បែររាជធានីភ្នំពេញ ។ បន្ថែមពីលើនេះ គណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្តសៀមរាប បានជូនព័ត៌មានដល់ការិយាល័យអំពីការចោទប្រកាន់ចំពោះការធ្វើឃាត (នៅក្នុងមេសា ឧសភា និង ២ នៅក្នុងខែមិថុនា) មនុស្សចំនួន ៤ នាក់ ដែលត្រូវបានអះអាងថាជាសមាជិកគណបក្សប្រជាជនកម្ពុជានៅក្នុងខេត្តនេះ ។ របាយការណ៍នេះគឺជាសេចក្តីសង្ខេបនៃព័ត៌មានដែលទទួលបាន និងបានធ្វើការវិភាគ រហូតមកទល់ថ្ងៃនេះនូវករណីសំខាន់ ២ បំផុតនៃករណីទាំងនេះ និងពិនិត្យឡើងវិញនូវករណីទាំងឡាយដែលបានរាយការណ៍លើកមុន ២ មក ។

ការបំភិតបំភ័យសមាជិក និងអ្នកគាំទ្រគណបក្សប្រឆាំង ក៏ដូចជាអ្នកបោះឆ្នោត ដោយអាជ្ញាធរមូលដ្ឋាន ចេះតែត្រូវបានរាយការណ៍មកជាបន្តបន្ទាប់ថាបានកើតមានឡើងនៅក្នុងរាជធានីភ្នំពេញ និងនៅតាមខេត្តនានា ។ ការនេះហាក់ដូចជាបានកើនឡើងនៅក្នុងខេត្តខ្លះ ដូចជាខេត្តកំពង់ធំជាដើម នៅក្នុងពេលដែលការបោះឆ្នោតកាន់តែខិតជិតចូលមកដល់ ។ ការធ្វើការបោះឆ្នោតសាកល្បង ដែលជារូបភាពថ្មីមួយនៃការបំភិតបំភ័យអ្នកបោះឆ្នោត ត្រូវបានរាយការណ៍មកថា បានកើតមានឡើងយ៉ាងហោចណាស់នៅក្នុងខេត្តចំនួន ៩ ។

ចាប់តាំងពីថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៩៨ មក ករណីចំនួន ៧៦ ករណី នៃការចោទប្រកាន់អំពីអំពើហិង្សា ឬការបំភិតបំភ័យដ៏ធ្ងន់ធ្ងរទាក់ទងនឹងការបោះឆ្នោតចំនួន ១៨៩ ករណី ត្រូវបានបញ្ជាក់ថាពិត ឬត្រូវបានវាយតម្លៃថាគួរឱ្យជឿទុកចិត្តបាន ។ ករណីទាំងនេះ មានភ្ជាប់មកជាឧបសម្ព័ន្ធនៃរបាយការណ៍នេះ ។ ការចោទប្រកាន់ទាំងឡាយដែលធ្វើឡើងដោយគ្មានមូលដ្ឋាន ឬដែលគ្មានទាក់ទិននឹងការបោះឆ្នោតទេនោះ ត្រូវបានដកចេញ រីឯករណីដែលមិនទាន់អាចបញ្ជាក់បានថាយ៉ាងណាទេនោះ កំពុងត្រូវពិនិត្យពិច័យ ។ ក្នុងរយៈពេលដដែលនេះដែរ ការិយាល័យបានធ្វើការស៊ើបអង្កេតទាំងអស់លើករណីឃាតកម្មចំនួន ១៣ ករណី ការចោទប្រកាន់អំពីឃាតកម្មចំនួន ៤ ករណី ការប៉ុនប៉ងធ្វើឃាតចំនួន ៣ ករណី ការចាប់ខ្លួន និងការឃុំខ្លួនមនុស្សដោយខុសច្បាប់ចំនួន ៧ ករណី ការរំលោភលើរូបរាងកាយចំនួន ៦ ករណី ការប៉ុនប៉ងចាប់ពង្រត់ចំនួន ១ ករណី និងករណីចំនួនជាង ១៥០ នៃការចោទប្រកាន់ស្ដីពីការគំរាមកំហែងផ្សេងៗ និងការបំភិតបំភ័យ ទាក់ទងទៅនឹងកិច្ចដំណើរការបោះឆ្នោត ។

លោកតំណាងពិសេស បានទាក់ទាញអារម្មណ៍អាជ្ញាធរជាពិសេសចំពោះករណីឃាតកម្ម ការប៉ុនប៉ងធ្វើឃាត និងអំពើហិង្សា ហើយបានសុំយ៉ាងទទូចឱ្យធ្វើការស៊ើបអង្កេតលើករណីទាំងអស់នេះ ។ លោកតំណាងពិសេស និងការិយាល័យប្រចាំកម្ពុជា សូមមិនធ្វើការវិនិច្ឆ័យអ្វីណាមួយឡើយ ចំពោះករណីទាំងនេះ ឬករណីណាដទៃទៀត ។ ដូចពីអតីតកាលមកដែរ តួនាទីរបស់ខ្លួនគឺបន្តជួយអាជ្ញាធរ និងប្រជាពលរដ្ឋកម្ពុជា ដើម្បីរកឱ្យឃើញនូវបញ្ហាសិទ្ធិមនុស្សទាំងឡាយដែលត្រូវដោះស្រាយដោយអាជ្ញាធរខាងការដាក់ឱ្យអនុវត្តន៍ច្បាប់ និងអាជ្ញាធរមានពាក់ព័ន្ធដទៃទៀត ។

របាយការណ៍ពិស្តារ:

<u>១- បច្ចុប្បន្នភាពនៃករណីដែលបានរាយការណ៍ពីមុន ១ មក:</u>

- មន្ត្រីតុលាការខេត្តព្រៃវែង បានផ្តល់យោបល់ថាពួកអស់លោកគ្មានភស្តុតាងគ្រប់គ្រាន់ ដើម្បីកាត់ទោសជនសង្ស័យ ២ នាក់ ដែលត្រូវបានចាប់ខ្លួន ទាក់ទិនទៅនឹងឃាតកម្មលើសមាជិកគណបក្សរាស្ត្រនិយមម្នាក់ឈ្មោះ ភិន ភន កាលពីថ្ងៃទី ១៤ ខែមិថុនា នោះទេ ។ សព្វថ្ងៃ អ្នកទាំង ២ នាក់ ត្រូវបានដោះលែងវិញហើយ ។

- របាយការណ៍របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ៧ ខែកក្កដា ស្តីពីការស៊ើបអង្កេតលើករណីឃាតកម្មលើរូបលោកស្រី មុំ យ៉េង នៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង បានសន្និដ្ឋានថា ជនល្មើសគឺជាកូនប្រសាប្រុសរបស់ជនរងគ្រោះ ហើយមូលហេតុនៃឃាតកម្មនេះគឺជាបញ្ហាបុគ្គល មិនមែនរឿងនយោបាយទេ ។

- ស្នងការនគរបាលខេត្តសៀមរាប (មកពីគណបក្សប្រជាជនកម្ពុជា) បានប្រាប់អង្គការក្រៅរដ្ឋាភិបាលការពារសិទ្ធិមនុស្សមួយថា លោកបានដឹងថាឃាតកម្មលើសមាជិកគណបក្សប្រជាជនកម្ពុជាចំនួន ៣ នាក់ កាលពីថ្ងៃទី ២៧ ខែឧសភា (សូមអានរបាយការណ៍ទី ២) មិនមែនជាឃាតកម្មនយោបាយទេ ។ ប្រធានគណបក្សខេត្ត របស់គណបក្សប្រជាជនកម្ពុជា បានថ្លែងប្រាប់ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាថា លោកមិនច្បាស់ថាករណីនេះមានលក្ខណៈនយោបាយ ឬយ៉ាងណានោះទេ ។ ទស្សនៈទាំងនេះ ស្របគ្នានឹងការថ្លែងរបស់សាក្សី ២ នាក់ ។

- តុលាការខេត្តកំពង់ចាម បានជូនដំណឹងមកការិយាល័យថា មន្ត្រីថ្នាក់ស្រុករបស់គណបក្សហ្វ៊ុនស៊ិនប៉ិចម្នាក់ឈ្មោះ ហ៊ួង សារុន នឹងត្រូវដោះលែងក្នុងពេលឆាប់ ៗ ខាងមុខនេះ ។ លោក ហ៊ួង សារុន ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ២៥ ខែមិថុនា នៅពេលគាត់ត្រឡប់មកពីចូលរួមការប្រមូលផ្តុំនយោបាយមួយចូលរួមដោយព្រះអង្គម្ចាស់រណឫទ្ធិ ហើយត្រូវបានជាប់ឃុំពីបទចោទថាមានគ្រាប់បែកដៃដោយខុសច្បាប់មួយគ្រាប់ ។ ក៏ប៉ុន្តែ រហូតមកដល់ថ្ងៃទី ១៧ ខែកក្កដា គាត់នៅតែនៅជាប់នៅក្នុងការឃុំឃាំងនៅឡើយ ។

- <u>ការកែតម្រូវ:</u> សមាជិកគណបក្សសមរង្ស៊ី ២ នាក់ដែលត្រូវបានចាប់ឃុំដោយខុសច្បាប់ដោយអាជ្ញាធរភូមិលេខ ១៥ នៃរាជធានីភ្នំពេញនោះ ការពិតគឺបានជាប់ឃុំនៅថ្ងៃទី ៥ ខែកក្កដា គឺមិនមែនថ្ងៃទី ២៨ ខែមិថុនា ដូចដែលបានចែងនៅក្នុងរបាយការណ៍លើកមុននោះទេ ។

២- ករណីថ្មី ១ ដែលកំពុងស្ថិតនៅក្នុងការស៊ើបអង្កេត:

ឃាតកម្មលើឈ្មោះ តិត តិម នៅក្នុងខេត្តកំពង់ធំ:

ឈ្មោះ តិត តិម ដែលត្រូវបានគេស្គាល់ថាជាឈ្មោះ ស្មាន់ តិម ដែរនោះ អាយុ ៦០ ឆ្នាំ ត្រូវបានបាញ់សម្លាប់នៅព្រឹកថ្ងៃទី ៥ ខែកក្កដា នៅពេលគាត់កំពុងដើរពីមុខកូនស្រី ២ នាក់របស់គាត់ ដើម្បីទៅថែទាំស្រែដែលស្ថិតនៅជិតភូមិរបស់គាត់ នៅក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ គាត់ជាសមាជិកគណបក្សហ៊្វុនស៊ិនប៉ិចតាំងពីយូរយាមកហើយ ប៉ុន្តែអាជ្ញាធរមូលដ្ឋានទើបតែបានដឹងអំពីខ្សែរយៈនយោបាយរបស់គាត់ នៅពេលដែលរូបគាត់ត្រូវបានក្លាយជាអ្នកសង្កេតការណ៍របស់គណបក្សហ៊្វុនស៊ិនប៉ិចនៅក្នុងភូមិរបស់គាត់ប៉ុណ្ណោះ ។ ពួកអ្នកវាយប្រហារ បានពួននៅក្នុងគុម្ពោតព្រៃចាំស្ទាក់វាយប្រហារទៅលើរូបគាត់ ។ នគរបាលបាននិយាយថា ពួកអ្នកបាញ់ប្រហារបានប្រើបានប្រើកាំភ្លើង អឹម-១៦ ឬ អាអែ-១៥ ហើយថាកាំភ្លើងប្រភេទនេះមានតែចំនួន ១៦ ដើមប៉ុណ្ណោះនៅក្នុងឃុំ ហើយទាំងអស់សុទ្ធតែជារបស់អាជ្ញាធរមូលដ្ឋាន ។ ពួកគេក៏បានថ្លែងផងដែរថា ការបាញ់ប្រហារនេះគឺជាការសងសឹកចំពោះការដែលគេចោទថាគាត់គឺជា "មេធ្មប់" ។ ការរកឃើញជាបឋម បានឱ្យដឹងថាឃាតកម្មនេះអាចបណ្តាលមកពីបញ្ហានយោបាយផង និងបញ្ហាផ្ទាល់ខ្លួនផង ។ ទន្ទឹមនឹងករណីនេះ គួរកត់សំគាល់ផងដែរអំពីឃាតកម្មលើរូបឈ្មោះ ថោង សួយ កាលពីថ្ងៃទី ២៤ ខែមិថុនា នៅក្នុងស្រុកសន្ទុកដែលស្ថិតនៅក្បែរគ្នានោះដែរ (សូមអានរបាយការណ៍លើកមុន) ។

ការរកឃើញសាកសពមិនស្គាល់អត្តសញ្ញាណមួយនៅក្នុងខេត្តកណ្តាល (ឃាតកម្ម)

សាកសពមនុស្សមិនស្គាល់អត្តសញ្ញាណម្នាក់ ដែលមានស្លាកស្នាមនៃឃាតកម្ម ត្រូវបានអ្នកភូមិឃើញអណ្តែតទឹកនៅក្នុងស្ទឹងមួយ នៃស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី ៤ ខែកក្កដា ។ សាក្សីដែលសម្ភាសន៍ដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បាននិយាយថាសាកសពនោះត្រូវចងដោយខ្សែនីឡុងនៅទីឯក និងជើងម្ខាង ហើយឃើញមានរន្ធនៅក្បាលផ្នែកខាងក្រោយ និងនៅលើខ្នងផ្នែកខាងក្រោម អាចជាស្នាមគ្រាប់កាំភ្លើង ។

ការប៉ុនប៉ងធ្វើឃាតចំនួន ២ លើក នៅក្នុងខេត្តកំពង់ឆ្នាំង និងខេត្តព្រៃវែង:

- នៅយប់ថ្ងៃទី ១៥ ខែមិថុនា មនុស្សមិនស្គាល់មុខ ៣ នាក់ ក្នុងនេះម្នាក់ស្លៀកពាក់ឯកសណ្ឋានទាហាន និងប្រដាប់ដោយកាំភ្លើងអាកាបត់ បានប៉ុនប៉ងសម្លាប់អ្នកព្យាបាលជម្ងឺ និងជាអ្នកលក់ថ្នាំពេទ្យម្នាក់ផង នៅក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ អ្នកព្យាបាលជម្ងឺរូបនេះ បានចុះឈ្មោះជាអ្នកសង្កេតការណ៍បោះឆ្នោតម្នាក់របស់គណបក្ស ហ៊្វុន

ស៊ិនប៊ិច នៅក្នុងឃុំរបស់គាត់ ហើយទទួលបន្ទុកជ្រើសរើសអ្នកសង្កេតការណ៍ចំនួន ១៦ នាក់ផ្សេងទៀត ។ វេលាប្រមាណម៉ោង ១០ កន្លះយប់ មនុស្ស ៣ នាក់បានចូលមកក្នុងផ្ទះគាត់ ហើយបានហៅចំឈ្មោះគាត់ ហើយថាពួកគេចង់ទិញថ្នាំ ។ ដោយខ្លាចមានគ្រោះថ្នាក់ គាត់បានឱ្យភរិយារបស់គាត់ឆ្លើយតបទៅវិញ ។ នៅពេលភរិយារបស់គាត់ហុចថ្នាំទៅឱ្យ ពួកគេម្នាក់មិនទទួលយកថ្នាំទេ តែបានចាប់ដៃគាត់ជាប់ ហើយរុញគាត់ឱ្យដួលទៅលើដី ព្រមទាំងភ្ជង់កាំភ្លើងទៅលើកញ្ចឹងកគាត់ថែមទៀត ។ ភរិយាគាត់បានស្រែកឡោឡាឡើង ហើយប្រាប់ប្ដីគាត់ឱ្យយកកាំភ្លើងចេញមក ។ នៅពេលនោះអ្នកទាំង ៣ នាក់ បានរត់គេចខ្លួន ព្រមទាំងបាញ់ ២ គ្រាប់ផង តែពុំមានត្រូវអ្នកណាទេ ។ បងប្អូនសាច់ញាតិរបស់គាត់បានទៅប្ដឹងប្រធានភូមិ តែប្រធានភូមិមិនបានធ្វើអន្តរាគមន៍អ្វីទេ ។ គាត់បានថ្លែងថា បន្ទាប់ពីឧប្បត្តិហេតុនេះ សមាជិកគណបក្សហ៊្វុនស៊ិនប៉ិចម្នាក់បានរត់មកចូលគណបក្សប្រជាជនកម្ពុជា ហើយអាចមាន ៣ នាក់ទៀតនឹងធ្វើដូចគ្នានេះដែរ ។ ការរកឃើញជាបឋម បង្ហាញថាករណីនេះអាចបណ្ដាលមកពីមូលហេតុនយោបាយ ។

- នៅយប់ថ្ងៃទី ១០ ខែកក្កដា អ្នកភូមិម្នាក់ដែលជាតំណាងរងប្រចាំឃុំរបស់គណបក្សហ៊្វុនស៊ិនប៉ិច បានរងរបួសដោយគ្រាប់កាំភ្លើង នៅក្នុងការប៉ុនប៉ងសម្លាប់រូបគាត់ ដែលបានកើតមានឡើងនៅក្នុងភូមិរបស់គាត់ ស្ថិតនៅក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង ។ មនុស្សប្រដាប់ដោយអាវុធ ២ នាក់ ដែលគាត់មិនដែលស្គាល់សោះ បានចូលមកក្នុងផ្ទះគាត់ ហើយភ្លាមនោះក៏បាញ់តម្រង់ទៅលើគាត់ នៅពេលដែលពួកគេឃើញគាត់ ។ គ្រាប់កាំភ្លើងមួយគ្រាប់បានត្រូវភ្លៅរបស់គាត់ គាត់ក៏បានរត់ចេញពីទីនោះទៅពួន ។ ព្រឹកថ្ងៃបន្ទាប់ គាត់ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ ។ គាត់មិនហ៊ានត្រឡប់ទៅកាន់ភូមិរបស់គាត់វិញទេ ដោយខ្លាចគេតាមសម្លាប់គាត់ទៀត ។ ការប៉ុនប៉ងធ្វើឃាតនេះ បានកើតមានឡើងបន្ទាប់ពីមានការឃាយី និងការគំរាមកំហែងជាច្រើនលើកច្រើនសាមកហើយ ទាក់ទិនទៅនឹងបញ្ហាជម្លោះដីធ្លី ចាប់តាំងពីពេលដែលជនរងគ្រោះបានចូលគណបក្សហ៊្វុនស៊ិនប៉ិចនៅឆ្នាំ ១៩៩២ មក ដែលបានប្រព្រឹត្តឡើងដោយអ្នកភូមិដ៏ទៃទៀតដែលចូលខាងគណបក្សប្រជាជនកម្ពុជា ។ ការរកឃើញជាបឋម បង្ហាញឱ្យឃើញថាករណីនេះ អាចជាបញ្ហាបុគ្គលផង និងនយោបាយផង ។

ការវាយប្រហារដោយគ្រាប់បែកដៃចំនួន ២ លើក នៅក្នុងរាជធានីភ្នំពេញ:

គ្រាប់បែកដៃមួយគ្រាប់ បានផ្ទុះនៅជិតសួនកំសាន្តមួយនៃរាជធានី នៅយប់ថ្ងៃទី ៦ ខែកក្កដា សិតនៅកណ្ដាលក្រុងភ្នំពេញតែម្ដង បណ្ដាលឱ្យស្លាប់មនុស្សម្នាក់ និងរបួស ៨ នាក់ផ្សេងទៀត ។ នៅក្នុងឧប្បត្តិហេតុលើកទី ២ កាលពីថ្ងៃទី ៩ ខែកក្កដា គ្រាប់បែក ២ គ្រាប់ត្រូវបានគប់ចូលទៅក្នុងបរិវេណផ្ទះរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តែគ្រាប់បែកនោះមិនបានផ្ទុះទេ ។ រហូតមកទល់ពេលនេះ ការិយាល័យពុំបានរកឃើញភស្តុតាងដែលថាករណីទាំង ២ នេះមានជាប់ពាក់ព័ន្ធទៅនឹងកិច្ចដំណើរការបោះឆ្នោតនោះទេ ។

ការចោទប្រកាន់អំពីករណីឃាតកម្មចំនួន ៤ ករណី នៅក្នុងខេត្តសៀមរាបៈ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបញ្ជូនមកកាន់ការិយាល័យនូវពាក្យបណ្តឹងចំនួន ៤ ស្តីពីឃាតកម្មលើសមាជិក ៤ នាក់របស់គណបក្សប្រជាជនកម្ពុជា ។ ពាក្យបណ្តឹងទាំងនេះ ទាក់ទិនទៅនឹងការចោទប្រកាន់អំពីឃាតកម្ម ដែលបានកើតមានឡើងនៅក្នុងឃុំដូនពែង នៅថ្ងៃទី ១១ ខែមេសា ថ្ងៃទី ៨ ខែឧសភា និងថ្ងៃទី ២៧ ខែមិថុនា ទៅ លើអ្នកភូមិភេទប្រុសចំនួន ៣ នាក់ ដែលមានអាយុ ៧៤ ៥៦ និង៤៦ ឆ្នាំ និងការចោទប្រកាន់ស្តីពីឃាតកម្មកាលពីថ្ងៃទី ២៦ ខែឧសភា ទៅលើអ្នកភូមិម្នាក់អាយុ ៦៦ ឆ្នាំ ។ អាជ្ញាធរឃុំ មកពីគណបក្សប្រជាជនកម្ពុជា បានថ្លែងថាឃាតកម្មទាំង ៤ លើកនេះគឺជាឃាតកម្មនយោបាយ ប៉ុន្តែមិនបានប្រាប់ឈ្មោះជនល្មើសទេ ។ ប្រធានគណបក្សប្រជាជនខេត្តបានប្រាប់ការិយាល័យនៅថ្ងៃទី ១៥ ខែមិថុនា ថាលោកមិនបានដឹងអំពីករណីទាំងនេះទេ ។ ការិយាល័យកំពុងធ្វើការស៊ើបអង្កេតករណីទាំងនេះ ។

៣- ករណីសំខាន់ ១ ដ៏ទៃទៀត នៃការបំភិតបំភ័យ និងអំពើហិង្សាៈ

ការដកហូតប័ណ្ណបោះឆ្នោតដោយអាជ្ញាធរមូលដ្ឋាន ដែលហាក់ដូចជាត្រូវបានធ្វើឡើងដើម្បីបញ្ជាក់ការគត់ត្រាទុកនូវលទ្ធផលឯកទេគ្គៈរបស់ពួកគេ កំពុងបន្តកើតមាននៅតាមខេត្តមួយចំនួន ។ ឧទាហរណ៍ នៅក្នុងស្រុកមួយនៃខេត្តកំពង់ធំ សមាជិកគណបក្សប្រឆាំងត្រូវបានគេដកហូតប័ណ្ណរបស់ពួកគេជាច្រើនលើកច្រើនសាមកហើយ ។ ពួកគេត្រូវបានទទួលប័ណ្ណមកវិញតែនៅក្រោយពេលមានអន្តរាគមន៍របស់តំណាងរបស់ពួកគេជាមួយអាជ្ញាធរមូលដ្ឋានប៉ុណ្ណោះ ។ ករណីដូចគ្នានេះ បានកើតមានឡើងនៅក្នុងខេត្តសៀមរាបផងដែរ កាលពីដើមខែកក្កដា ។

របាយការណ៍មួយនៃការបំភិតបំភ័យដល់អ្នកបោះឆ្នោត ត្រូវបានរាយការណ៍មកក្នុងអាទិត្យកន្លងទៅនេះ ពីខេត្តមួយចំនួន នោះគឺៈ មានការបោះឆ្នោតសាកល្បងរៀបចំឡើងដោយមន្ត្រីភូមិ និង/ឬឃុំ និងដោយអ្នកគ្រប់គ្រងរោងចក្រនានា ។ ជាទូទៅ ការធ្វើនេះត្រូវបានធ្វើឡើងចំពោះអ្នកភូមិ ឬកម្មករ ដែលត្រូវបានកោះឱ្យចូលរួមប្រជុំ ហើយនៅពេលនោះពួកគេត្រូវបានគេប្រាប់ឱ្យគូសលើសន្លឹកឆ្នោតដែលត្រូវបោះ ហើយបន្ទាប់មកមានការត្រួតពិនិត្យមើលដើម្បីធានាថាអ្នកចូលរួមបានធ្វើការជ្រើសរើសគណបក្សប្រជាជនកម្ពុជាដោយត្រឹមត្រូវហើយ ។ ពេលនេះ ការិយាល័យកំពុងធ្វើការស្រាវជ្រាវឧប្បត្តិហេតុប្រភេទនេះ នៅក្នុងខេត្តតាកែវ ខេត្តកណ្តាល ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ។

ទន្ទឹមនឹងនេះ ការិយាល័យក៏កំពុងធ្វើការផ្ទៀងផ្ទាត់ផងដែរ នូវករណីទាំងឡាយដូចខាងក្រោមនេះៈ

- ការតាមឃ្លាំមើលជាញឹកញាប់នៅពេលយប់ ចាប់តាំងពីថ្ងៃទី ៦ ខែកក្កដា មក នូវផ្ទះបេក្ខជនតំណាងរាស្ត្ររបស់គណបក្សហ៊្វុនស៊ិនប៉ិចម្នាក់ នៅក្នុងខេត្តពោធិសាត់ ដោយក្រុមមនុស្សមិនស្គាល់មុខចំនួន ៣ នាក់ ។

- ការឃ្លាំមើល និងការតាមដានដោយចំហ ដោយមនុស្សមិនស្គាល់មុខជាច្រើននាក់ ទៅលើបេក្ខជនតំណាងរាស្ត្រថ្នាក់ខ្ពស់ និងសកម្មម្នាក់របស់គណបក្សហ៊្វុនស៊ិនប៉ិច សំរាប់មណ្ឌលខេត្តតាកែវ នៅក្នុងខេត្តតាកែវ និងនៅភ្នំពេញ នៅថ្ងៃទី ៨ និងទី ៩ ខែកក្កដា កន្លងទៅនេះ ។

- ការវាយដំទៅលើស្ត្រីអ្នកគាំទ្រគណបក្សសមរង្ស៊ីម្នាក់នៅក្នុងផ្ទះរបស់គាត់ ស្ថិតនៅជិតទីក្រុងបាត់ដំបង កាលពីថ្ងៃទី ១០ ខែកក្កដា ដោយប្រធានសាខាគណបក្សប្រជាជនកម្ពុជា ដែលតាមសេចក្ដីរាយការណ៍ថាគាត់ត្រូវបានចោទប្រកាន់ថាបានចូលរួមក្បួនដង្ហែរបស់គណបក្សសមរង្ស៊ីនៅក្នុងក្រុងបាត់ដំបងនាថ្ងៃដដែលនោះ ។

- កាលពីថ្ងៃទី ១០ ខែកក្កដា បេក្ខជនតំណាងរាស្ត្ររបស់គណបក្សហ៊្វុនស៊ិនប៉ិចម្នាក់សំរាប់មណ្ឌលខេត្តកោះកុងបានទទួលការហៅទូរស័ព្ទពីមនុស្សម្នាក់ដែលបដិសេធមិនព្រមប្រាប់ឈ្មោះរបស់គេដល់គាត់ ។ ការហៅតាមទូរស័ព្ទនេះគឺដើម្បីអញ្ជើញគាត់ឱ្យទៅជួបសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅកន្លែងដែលបានកំណត់មួយ ។ បន្ទាប់ពីធ្វើការបញ្ជាក់មកឃើញថាពុំមានការអញ្ជើញទៅប្រជុំណាមួយបែបនេះ ត្រូវបានស្នើឡើងដោយលោករដ្ឋមន្ត្រីនោះទេ ។ នៅថ្ងៃទី ១១ ខែកក្កដា បេក្ខជនដដែលនេះ ត្រូវបានឃ្លាំមើលដោយមនុស្ស ៤ នាក់ក្នុងសម្លៀកបំពាក់ជាឯកសណ្ឋានអង្គរក្ស ដែលស្ថិតនៅក្បែរផ្ទះរបស់គាត់ ។

- មន្ត្រីថ្នាក់ខ្ពស់ម្នាក់របស់គណបក្សសមរង្ស៊ី បានទទួលការហៅទូរស័ព្ទអនាមិកមួយកាលពីថ្ងៃទី ១៤ ខែកក្កដាកន្លងទៅនេះ ដោយថ្លែងថាហៅមកពីក្រសួងមហាផ្ទៃ ហើយបានប្រាប់គាត់ថាបើសិនជាគាត់ហ៊ានទៅព្រលានយន្តហោះពោធិចិនតុងដើម្បីឡើងយន្តហោះទៅខេត្តសៀមរាបនោះ គាត់នឹងត្រូវចាប់ខ្លួន ។ អ្នកហៅទូរស័ព្ទបានចោទប្រកាន់មន្ត្រីរូបនោះថាជាអ្នករៀបចំធ្វើបាតុកម្ម និងជាអ្នកទទួលខុសត្រូវក្នុងការវាយប្រហារដោយគ្រាប់បែកនាថ្ងៃទី ៣០ ខែមីនាឆ្នាំ ទៅមិញ ហើយនឹងការគប់គ្រាប់បែក ២ លើកទៀតនៅក្នុងទីក្រុងភ្នំពេញកាលពីអាទិត្យកន្លងទៅនេះ ។

- ស្ត្រីម្នាក់ដែលមានជាប់ពាក់ព័ន្ធជាមួយគណបក្សហ៊្វុនស៊ិនប៉ិច ហើយដែលត្រូវបានឃុំខ្លួនដោយខុសច្បាប់កាលពីដើមឆ្នាំនេះ ដោយយោធាខេត្តកោះកុង ត្រូវបានមនុស្សមិនស្គាល់អត្តសញ្ញាណ ២ នាក់ មកទាក់ទងជាមួយនាងនៅក្នុងផ្សារច្បារអំពៅ ក្រុងភ្នំពេញ កាលពីថ្ងៃទី ១៣ ខែកក្កដាកន្លងទៅនេះ ហើយបានសួរនាងអំពីសកម្មភាព និងផែនការរបស់គណបក្សនាង ។ គ្នាគេម្នាក់ដែលស្លៀកពាក់ឯកសណ្ឋានយោធា និងជិះម៉ូតូមានផ្លាកយោធាបានទះកំភ្លៀងនាងមួយ

ដែរ ព្រមទាំងបានគំរាមកំហែងថានឹងសម្លាប់ប្តី និងកូន ១ របស់នាង បើនាងនៅតែមិនព្រមផ្តល់ពត៌មានដែលពួកគេបានទាមទារនាងទេនោះ ។ មុននេះកូនស្រីរបស់គាត់ធ្លាប់ត្រូវបានមនុស្សម្នាក់ស្លៀកពាក់ជាយោធាមកសួរនាងចំនួន ២ ដង អំពីខ្សែរយៈនយោបាយរបស់ឪពុកម្តាយនាង ។

- នៅថ្ងៃទី ៩ ខែកក្កដា មន្ត្រីម្នាក់របស់អង្គការខុមប្រែល ដែលកំពុងធ្វើដំណើរទៅកាន់តំបន់អន្លង់វែង ដើម្បីបញ្ចប់ការជ្រើសរើសអ្នកសង្កេតការណ៍ចំនួន ៦ នាក់ សំរាប់ឃុំពីរនៅក្នុងស្រុក ត្រូវបានទទួលការគំរាមកំហែងពីសំណាក់អភិបាលស្រុកថ្មី ដែលជាអតីតកម្មាភិបាលថ្នាក់ខ្ពស់ខ្មែរក្រហមមួយរូប ។ អភិបាលស្រុករូបនេះ បានធ្វើការព្រមានមន្ត្រីនោះថា មិនបានសុំច្បាប់គាត់ដើម្បីទៅធ្វើការជ្រើសរើសអ្នកសង្កេតការណ៍ ៦ នាក់នោះ ។ គាត់បានគំរាមកំហែងថានឹងចាប់ខ្លួនមន្ត្រីនោះ ហើយបានប្រាប់គាត់ថា "អង្គការខុំប្រែល និងសិទ្ធិមនុស្ស" មិនត្រូវបានស្វាគមន៍មកក្នុងស្រុករបស់គាត់ទេ ហើយថាមន្ត្រីរូបនោះមិនត្រូវមកនៅទីនេះទេ ពីព្រោះថា "មានតែច្បាប់កុម្មុយនិសទេ" នៅទីនេះ ។

ការិយាល័យ ក៏កំពុងធ្វើការស៊ើបអង្កេតចំពោះការចោទប្រកាន់ដែលថា កាលពីថ្ងៃទី ១៣ ខែកក្កដា វេលាប្រមាណម៉ោង ១០ យប់ មនុស្ស ២ នាក់បានបាញ់ដោយកាំភ្លើងអាកា-៤៧ ចំនួន ៦គ្រាប់ ទៅលើរថយន្តមួយបើកបរដោយឈ្មោះ ប៊ុល សុធា តាមផ្លូវមួយនៅក្នុងខ័ណ្ឌទួលគក ក្រុងភ្នំពេញ ។ ឈ្មោះ ប៊ុល សុធា ជាបេក្ខជនលេខ ៥ របស់គណបក្សសមរង្ស៊ី សំរាប់មណ្ឌលខេត្តតាកែវ ។